**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៧៩ អនក្រ.បក**

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង**

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែងដែលមានផ្ទៃដីទំហំ ២៥.២៦៩,៤១ ហិកតា (ពីរម៉ឺនប្រាំពាន់ពីររយហុកសិបប្រាំបួនហិកតាសែសិបមួយអា) ស្ថិតក្នុងភូមិសាស្ត្រស្រុកត្បែងមានជ័យ ស្រុកសង្គមថ្មី ស្រុកគូលែន ស្រុករវៀង និងក្រុងព្រះវិហារ នៃខេត្តព្រះវិហារ ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកា(Datum: WGS1984) ដូចខាងក្រោម៖

| និយាមកាគោល | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ID | X | Y | ID | X | Y | ID | X | Y |
| 1 | 492836 | 1503372 | 19 | 482918 | 1520889 | 37 | 492052 | 1521334 |
| 2 | 492605 | 1505329 | 20 | 480871 | 1521217 | 38 | 493036 | 1519595 |
| 3 | 492772 | 1507314 | 21 | 478885 | 1521433 | 39 | 493669 | 1517697 |
| 4 | 491538 | 1508765 | 22 | 476930 | 1521414 | 40 | 493755 | 1515753 |
| 5 | 490360 | 1509588 | 23 | 474950 | 1521359 | 41 | 495097 | 1514520 |
| 6 | 488448 | 1509003 | 24 | 473432 | 1522629 | 42 | 495839 | 1512663 |
| 7 | 486852 | 1509851 | 25 | 472064 | 1524055 | 43 | 496901 | 1510980 |
| 8 | 485289 | 1510912 | 26 | 471923 | 1525941 | 44 | 497484 | 1509154 |
| 9 | 484963 | 1512665 | 27 | 473752 | 1525881 | 45 | 499328 | 1509217 |
| 10 | 483725 | 1513458 | 28 | 475323 | 1524655 | 46 | 500305 | 1507534 |
| 11 | 481780 | 1513885 | 29 | 477117 | 1523808 | 47 | 499681 | 1505699 |
| 12 | 479788 | 1513960 | 30 | 479049 | 1523323 | 48 | 500778 | 1504028 |
| 13 | 478280 | 1515156 | 31 | 480813 | 1522552 | 49 | 501028 | 1502180 |
| 14 | 478393 | 1516852 | 32 | 482791 | 1522804 | 50 | 499193 | 1501906 |
| 15 | 479562 | 1517082 | 33 | 484784 | 1522967 | 51 | 497243 | 1502134 |
| 16 | 480152 | 1517063 | 34 | 486768 | 1523207 | 52 | 495342 | 1501635 |
| 17 | 480426 | 1518896 | 35 | 488761 | 1523279 | | | |
| 18 | 481713 | 1519605 | 36 | 490658 | 1522731 | | | |

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ការពារតួនាទីផ្នែកប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារ នៃតំបន់នេះ
- ការពារសោភ័ណ្ឌភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិ នៃតំបន់នេះសម្រាប់បម្រើដល់ការកំសាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវ វិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះពុំបង្កការគំរាមកំហែងដល់បរិស្ថាន ធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន



www.pheakdeylaw.com

- ផ្តល់សេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលដែនដីខេត្តព្រះវិហារ ដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com

# ផែនទី តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំត្បែង ស្ថិតក្នុងខេត្តព្រះវិហារ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ១៨៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ២០១៦




និយាមកាគោល

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 492836 | 1503372 | | | |
| 2 | 492605 | 1505329 | | | |
| 3 | 492772 | 1507314 | | | |
| 4 | 491538 | 1508765 | 29 | 475323 | 1524655 |
| 5 | 490360 | 1509588 | 30 | 477117 | 1523808 |
| 6 | 488448 | 1509003 | 31 | 479049 | 1523323 |
| 7 | 486852 | 1509851 | 32 | 480813 | 1522552 |
| 8 | 485289 | 1510912 | 33 | 482791 | 1522804 |
| 9 | 484963 | 1512665 | 34 | 484784 | 1522967 |
| 10 | 483725 | 1513458 | 35 | 486768 | 1523207 |
| 11 | 481780 | 1513885 | 36 | 488761 | 1523279 |
| 12 | 479788 | 1513980 | 37 | 490658 | 1522731 |
| 13 | 478280 | 1515156 | 38 | 492052 | 1521334 |
| 14 | 478393 | 1516852 | 39 | 493036 | 1519595 |
| 15 | 479562 | 1517082 | 40 | 493669 | 1517697 |
| 16 | 480152 | 1517063 | 41 | 493755 | 1515753 |
| 17 | 480426 | 1518896 | 42 | 495097 | 1514520 |
| 18 | 481713 | 1519605 | 43 | 495839 | 1512663 |
| 19 | 482918 | 1520889 | 44 | 496901 | 1510980 |
| 20 | 482859 | 1521016 | 45 | 497484 | 1509154 |
| 21 | 480871 | 1521217 | 46 | 499328 | 1509217 |
| 22 | 478885 | 1521433 | 47 | 500305 | 1507534 |
| 23 | 476930 | 1521414 | 48 | 499681 | 1505699 |
| 24 | 474950 | 1521359 | 49 | 500778 | 1504028 |
| 25 | 473432 | 1522629 | 50 | 501028 | 1502180 |
| 26 | 472064 | 1524055 | 51 | 499193 | 1501906 |
| 27 | 471923 | 1525941 | 52 | 497243 | 1502134 |
| 28 | 473752 | 1525881 | 53 | 495342 | 1501635 |

ព្រះវិហារ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦
អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ

ប៊ុន-ចាន់ដា

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១
រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

www.pheakdeylaw.com